ជំនឿលើខ្សែកឫសឈើនៅតំបន់កោះកេរ

បើទោះបីជាវិស័យសុខាភិបាលមានភាពទំនើបយ៉ាងណាក្តី ជំនឿជីវិតនៅតែដើរតួនាទីយ៉ាងសំខាន់នៅក្នុងជីវភាពរស់នៅរបស់អ្នកស្រុកនៅតំបន់កោះកេរ។ ក្រៅពីការជឿទៅលើពពួកអមនុស្ស អ្នកស្រុកមានជំនឿលើឫសឈើមួយប្រភេទ ដែលគេចាត់ទុកជាឱសថបុរាណយ៉ាងពូកែស័ក្តិសិទ្ធិ ដោយយកមកពាក់ជាប់ក ដើម្បីព្យាបាលជំងឺក្អែក ជាពិសេស គឺក្អែកឡើងបាយ និងក្អែកដុះកន្ទុយថ្ងែន។ នៅក្នុងអត្ថបទខ្លីនេះ យើងនឹងបង្ហាញអំពីជំនឿទៅលើខ្សែកធ្វើអំពីឫសឈើនៅតំបន់កោះកេរ។ តើជំនឿនេះមានលក្ខណៈដូចម្តេចខ្លះ?

ជាទូទៅ មានវត្ថុជាច្រើនដែលអ្នកស្រុកនៅតំបន់កោះកេរនិយមយកមកធ្វើជាបន្ទោងខ្សែក ដូចជា ខ្នាយតាន់ ចៃកាច់ ចង្កឹមខ្វា ព្រះពុទ្ធរូបតូចៗ និងចម្លាក់រូបឥសីជាដើម។ វត្ថុទាំងនេះ គេចាត់ទុកថាជាវត្ថុស័ក្តិសិទ្ធិ សម្រាប់ការពារខ្លួនពីការយាយី ឬបំណងអាក្រក់របស់ពពួកអមនុស្ស។ ចំណែកឯខ្សែកឫសឈើវិញ គេនិយមពាក់ច្រើនគួរសម ជាពិសេសមនុស្សចាស់ៗដែលតែងជួបបញ្ហាក្អែកឡើងបាយ និងក្អែកដុះកន្ទុយថ្ងែន។ ប្រភេទដើមថ្នាំដែលយកមកផ្សំ គឺមានចំនួនតិចឬច្រើន អាស្រ័យលើការចេះចាំតពីគ្រូមុនៗរបស់ខ្លួន។ ឧទាហរណ៍ អ្នកភូមិស្រុយង់ត្បូងមួយចំនួនបានវេញខ្សែកមួយខ្សែដោយប្រើប្រាស់ឫសឈើជាច្រើនមុខរួមគ្នា ដូចជា ឫសខ្នែងពណ៌ ឫសកន្ទ្រែង ឫសក្រូចឆ្មារ ឫសត្រប់ខារ និងឫសត្រប់ម្ជូយ ជាដើម (រូបលេខ១)។ អ្នកខ្លះទៀត គេនិយមប្រើប្រាស់តែឫសកន្ទ្រែងមួយមុខប៉ុណ្ណោះ (រូបលេខ២)។ រីឯ អ្នកភូមិកោះកេរ និយមប្រើប្រាស់ឫសឈើមួយមុខដូចគ្នា ដូចជា ឫសត្រប់ម្ជូយ (រូបលេខ៣-៤) ឬឫសកន្ទ្រែងជាដើម ប៉ុន្តែ កន្ទ្រែងមានពីរប្រភេទ គឺកន្ទ្រែងមេ និងកន្ទ្រែងឈ្មោល (រូបលេខ៥-៦)។ ការពាក់ខ្សែកឫសឈើ ដើម្បីព្យាបាលជំងឺក្អែកឡើងបាយ ឬក្អែកដុះកន្ទុយថ្ងែនទាំងនេះ គេបម្រាមមិនអនុញ្ញាតឱ្យដោះចេញបានឡើយ ពោលគឺត្រូវពាក់ជាប់ខ្លួនរហូតដល់ដាច់ដោយឯកឯងតែម្តង (រូបលេខ៧)។ ប៉ុន្តែ មានគ្រូខ្លះទៀតតម្រូវឱ្យពាក់តែបីខែប៉ុណ្ណោះ ហើយអាចកាត់ចេញវិញបាន។

ចំណេះដឹងក្នុងការវេញឫសឈើធ្វើជាខ្សែកសម្រាប់ពាក់ព្យាបាលជំងឺក្អែកនេះ គេចេះតៗគ្នាពីសាច់ញាតិជំនាន់មុន។ គេជឿថា មុននឹងដកឫសឈើទាំងនេះ គេត្រូវយកគ្រាប់អង្ករដំណើបចំនួន ៧ គ្រាប់ រួចនិយាយឧបកិច្ចថា៖ "***ខ្ញុំ! លោកគ្រូដើមថ្នាំពូកែស័ក្តិសិទ្ធិអើយ ខ្ញុំសុំយកទៅចងក្អែកខ្ញុំគេ***"។ ការវេញជាខ្សែកនេះទៀតសោត គេមានត្រណមថា អាចវេញបានចំពោះតែថ្ងៃអង្គារ

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង

មួយប៉ុណ្ណោះ។ យើងមិនដឹងអំពីមូលហេតុនេះជាក់លាក់នោះទេ។ ប៉ុន្តែ ត្រណមនេះគឺមិនខុសពីពិធីឡើងអ្នកតានៅជុំវិញតំបន់ប្រាសាទសំបូរព្រៃគុកដែរ ព្រោះគេច្រើនរើសយកថ្ងៃអង្គារ និងថ្ងៃសៅរ៍ ដោយគេជឿថាជាថ្ងៃអមនុស្សចេញដើរ និងមានឥទ្ធិពលខ្លាំង។ ចំណុចដែលគួរឱ្យចាប់អារម្មណ៍នោះគឺ អំបោះសម្រាប់យកមកវេញត្រូវប្រើប្រាស់តែពីរពណ៌ប៉ុណ្ណោះ គឺពណ៌ស និងខ្មៅ ដោយតម្រូវឱ្យមានចំនួន ៧ សរសៃស្មើៗគ្នា។ ហេតុអ្វីបានជាគេតម្រូវប្រើត្រឹមពីរពណ៌នេះ? បើយើងពោលថា កាលដើមឡើយមានតែអំបោះពីរពណ៌នេះ ក៏មិនត្រឹមត្រូវទាំងស្រុងដែរ ព្រោះតាមអ្នកស្រុកបានបញ្ជាក់ថា ពណ៌ផ្សេងទៀតក៏មានដែរ តែគេតម្រូវឱ្យប្រើពីរពណ៌នេះប៉ុណ្ណោះ។ ម្ល៉ោះហើយ យើងអាចសន្និដ្ឋានបឋមថា ការជ្រើសរើសពណ៌ស និងខ្មៅ ប្រហែលជាមានទំនាក់ទំនងផ្ទាល់ទៅនឹងពណ៌នៃភ្នែកមនុស្ស ព្រោះភ្នែកមនុស្សមានតែពណ៌ស និងខ្មៅប៉ុណ្ណោះ។

សរុបមក ជំនឿលើការប្រើប្រាស់ខ្សែកឫសឈើនៅតំបន់កោះកេរ មិនត្រឹមតែជាបណ្តុំនៃចំណេះដឹងបុរាណក្នុងការថែទាំ និងព្យាបាលជំនឿភ្នែក (ដូចជាជំងឺភ្នែកឡើងបាយ និងភ្នែកដុះកន្ទុយថ្ងែន) តាមបែបជំនឿជីវចលប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងបង្ហាញឱ្យឃើញពីអត្តន័យ ទំនៀមទម្លាប់ និងការគោរពប្រតិបត្តិដ៏ផ្លូវផង់ដែលបានបន្តវេនពីបុព្វបុរសជំនាន់ដើមមកផងដែរ។ មិនថាតាមរយៈការជ្រើសរើសប្រភេទឫសឈើ ពិធីសុំ និងការកំណត់ថ្ងៃ ឬពណ៌អំបោះសនិងខ្មៅដែលទាក់ទងនឹងលក្ខណៈធម្មជាតិនៃភ្នែកនោះទេ រាល់សកម្មភាពទាំងអស់សុទ្ធសឹងបញ្ជាក់ពីចំណងទាក់ទងយ៉ាងជិតស្និទ្ធរវាងជីវិតមនុស្ស និងបរិស្ថានធម្មជាតិក្នុងតំបន់។ ទោះបីជាបច្ចុប្បន្នវិស័យវេជ្ជសាស្ត្រ និងសុខាភិបាលមានការរីកចម្រើនយ៉ាងណាក៏ដោយ ក៏ជំនឿប្រពៃណីនេះនៅតែបន្តរស់រាន និងឆ្លុះបញ្ចាំងពីអត្តសញ្ញាណវប្បធម៌ដ៏មានតម្លៃរបស់អ្នកស្រុកក្នុងតំបន់កោះកេរគួរឱ្យកត់សម្គាល់។

បញ្ជីឯកសារពិគ្រោះ

ម៉ង់ វ៉ាលី, អាន រស្មី, ស្រី សមប៊ុនណារ៉ុង, ២០២៥, *មត៌កអរូបីជុំវិញតំបន់សំបូរព្រៃគុក (ការសិក្សាស្រាវជ្រាវ និងចុះបញ្ជីកិច្ចពិធីបែបជីវបថល)*, ភ្នំពេញ។

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង

បទសម្ភាសន៍

១. លោក **ដឹម ឿន** អាយុ ៦៣ឆ្នាំ មេភូមិកោះកេរ និងជាអ្នកពាក់ផ្ចាល់

២. លោកយាយ **ហឿក** អាយុ ៩៥ ឆ្នាំ រស់នៅភូមិកោះកេរ ជាអ្នកវេញខ្សែក និងពាក់ផ្ចាល់

៣. លោកយាយ **ម៉ឿន** អាយុ ៦៧ ឆ្នាំ រស់នៅភូមិកោះកេរ និងជាអ្នកពាក់ផ្ចាល់

៤. លោកតា **សឿន** អាយុ ៧៨ ឆ្នាំ រស់នៅភូមិកោះកេរ ជាអ្នកវេញខ្សែក

៥. លោកយាយ **លៀន** អាយុ ៧២ ឆ្នាំ រស់នៅភូមិស្រយង់ត្បូង ជាអ្នកវេញខ្សែក និងពាក់ផ្ចាល់

៦. លោកតា **ដឹប លួន** អាយុ ៧៩ ឆ្នាំ រស់នៅភូមិស្រយង់ត្បូង ជាអ្នកវេញខ្សែក និងពាក់ផ្ចាល់

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION



រូបលេខ១៖ យាយ លុយ លៀន នៅភូមិស្រយង់ត្បូង



រូបលេខ២៖ តា ដឹប លូន នៅភូមិស្រយង់ត្បូង



រូបលេខ៣៖ យាយម៉ឿន នៅភូមិកោះកេរ



រូបលេខ៤៖ ដើមត្រប់មួយ



រូបលេខ៥៖ យាយបឿក នៅភូមិកោះកេរ



រូបលេខ៦៖ ដើមកន្ទុងមេ និងកន្ទុងឈ្មោល

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង



រូបលេខ៧៖ លោក ដឹម ឌឿន អាយុ ៦៣ឆ្នាំ មេភូមិកោះកេរ និងជាអ្នកពាក់ផ្ចាល់

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ស្រី សមប៊ុនណារ៉ុង